អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

ថ្ងៃទី ១ ខែ ឧសភា ឆ្នាំ ២០១២

# សេចក្តីប្រកាសព័ត៌មាន

## លោក ISAAC ENDELEY ត្រូវបានតែងតាំងជាប្រធានអង្គភាពគាំពារការការពារក្តី

ការិយាល័យរដ្ឋបាលនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក) មានក្តីសោមនស្សរីករាយសូមជូនដំណឹងអំពីការតែងតាំងលោក Isaac Endeley ជាប្រធានថ្មីនៃអង្គភាពគាំពារការការពារក្តី។ លោក Isaac Endeley បានចូលកាន់តំណែងនេះ កាលពីថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ២០១២។

ចាប់ពីឆ្នាំ ២០០៥ រហូតដល់ពេលផ្ទេរការងារមក អ.វ.ត.ក នេះ លោក Isaac Endeley បានបំពេញការងារជាមន្ត្រីច្បាប់នៅផ្នែកគាំពារអង្គជំនុំជម្រះ (Chambers Support) និងនៅផ្នែកមេធាវីការពារក្តី (Defence Counsel) និងការគ្រប់គ្រងមន្ទីរឃុំឃាំង (Detention Management) នៅតុលាការឧក្រិដ្ឋអន្តរជាតិរបស់អង្គការសហប្រជាជាតិសម្រាប់ប្រទេសរវ៉ាន់ដា (UNICTR) ដែលមានមូលដ្ឋាននៅទីក្រុងអារុស្សា (Arusha) ប្រទេសតង់សានី។ ក្នុងឋានៈជាមន្ត្រីច្បាប់ គាត់បានគ្រប់គ្រងកម្មវិធីជំនួយផ្នែកច្បាប់ (Legal Aid Programme) ដ៏ស្មុគស្មាញរបស់ UNICTR។ មុនពេលបំពេញការងារនៅអង្គការសហប្រជាជាតិ លោក Isaac Endeley បានបំពេញការងារជាមេធាវី-និពន្ធនាយក (Attorney-Editor) នៅក្រុមហ៊ុន WestLaw (ដែលបច្ចុប្បន្នមានឈ្មោះថា Thomson/Reuters) ជាក្រុមហ៊ុនស្រាវជ្រាវ និងបោះពុម្ពផ្សាយផ្នែកច្បាប់ដែលមានមូលដ្ឋាននៅទីក្រុងមីនីសូតា (Minnesota) សហរដ្ឋអាមេរិក។ មុនកាន់តំណែងនោះ គាត់ជាសាស្ត្រាចារ្យផ្នែកវិទ្យាសាស្ត្រនយោបាយ និងទំនាក់ទំនងអន្តរជាតិ នៅសាកលវិទ្យាល័យនានានៅសហរដ្ឋអាមេរិក និងកាណាដា។

លោក Isaac Endeley មានដើមកំណើតមកពីប្រទេសកាមេរូននៃទ្វីបអាហ្វ្រិក។ លោកទទួលបានសញ្ញាប័ត្របរិញ្ញាប័ត្រ និងវិញ្ញាបនប័ត្រផ្នែកអប់រំពីសាកលវិទ្យាល័យ Keele University នៅចក្រភពអង់គ្លេស សញ្ញាប័ត្រអនុបណ្ឌិត និងបណ្ឌិតពីសាកលវិទ្យាល័យ Université de Montréal នៅទីក្រុងកេបិច (Québec) ប្រទេសកាណាដា និងបានទទួលសញ្ញាប័ត្រ Juris Doctor ពីមហាវិទ្យាល័យច្បាប់ William Mitchell College of Law

នៅក្រុងមីនីសូតា សហរដ្ឋអាមេរិក។ នាពេលថ្មីៗនេះ លោក Isaac Endeley ក៏បាននិពន្ធសៀវភៅពីរក្បាលស្តីពីកិច្ចការអន្តរជាតិផងដែរ។

សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទង៖


**លោក ឡាស អូលសិន**
មន្ត្រីទំនាក់ទំនងផ្នែកច្បាប់
ទូរស័ព្ទចល័ត៖ +៨៥៥ (0) ១២ ៤៨៨ ០២៣
ទូរស័ព្ទ៖ +៨៥៥(0) ២៣ ២១៩ ៨១៤ លេខបន្ត៖ ៦១៦៩
សារអេឡិចត្រូនិក៖ olsenl@un.org

**លោក នេត្រ ភក្ត្រា**
អ្នកនាំពាក្យសាលាក្តីខ្មែរក្រហម
ទូរស័ព្ទដៃ៖ +៨៨៥(0) ១២ ៤៨៨ ១៥៦
សារអេឡិចត្រូនិក៖ neth.pheaktra@eccc.gov.kh




Original EN: 00803892-00803892